ងគោលដៅនៅក្នុងព្រះហឫទ័យរបស់ព្រះយេស៊ូវ! ប្រសិនបើគ្មានគោលដៅនេះទេ យើងនឹងបាត់បង់នូវគោលដៅនៃជីវិតមិនខាន ។

## សកម្មភាពនៃការបង្កើតរបស់ព្រះយេស៊ូវក្នុងព្រះគម្ពីរ សញ្ញាណាចាស់

តាមរយៈបទគម្ពីរ សុភាសិត ៨៖២២-២៤, ៣០ បានថែងមកថា៖ *"ព្រះយេហូវ៉ា ទ្រង់បាន តាំងអញឡើង ជាដើមការ នៃទ្រង់ គឺមុនអស់ទាំងកិច្ចការរបស់ទ្រង់ពីបុរាណ ទ្រង់បានសិត អញតាំងពីអស់កល្ប រៀងមក គឺពីកាលនៅដើមឡើយ មុនដែលមានផែនដីផង ក្នុងគ្រាមុនដែលមានទីជំរៅទឹក នោះអញបានកើតហើយ គឺកាលមិនទាន់មានរន្ធទឹកណាដែលហូរចេញជាបរិបូរនៅ ឡើយ.... នៅគ្រានោះ អញបាននៅជិតទ្រង់ដូចជាមេជាងហើយ អញជាទីគាប់ព្រះហឫទ័យទ្រង់រាល់ៗថ្ងៃព្រម ទាំងមាន សេចក្តីរីករាយនៅចំពោះទ្រង់ជានិច្ច"*។ ពាក្យថា៖ "មេជាង" បានប្រើប្រាស់ក្នុងបទគម្ពីរនេះ ក៏បានបញ្ជាក់អំពីសកម្មភាពរបស់ព្រះយេស៊ូវក្នុងការបង្កើតលោកផងដែរ។ នៅក្នុងខទី២៦ នៃទំនុក តម្កើង ១០២ គឺត្រូវបានដកស្រង់នៅក្នុងព្រះគម្ពីរសញ្ញាថ្មីក្នុងបទគម្ពីរហេព្រើរ ១៖១០ ហើយវាត្រូវបានប្រើសម្រាប់ព្រះយេស៊ូវ *"ហើយថា "ឱព្រះអម្ចាស់អើយ កាលដើមដំបូង ទ្រង់បានបង្កប្ញសផែនដី ហើយផ្ទៃមេឃក៏ ជាការដែលព្រះហស្តទ្រង់ធ្វើដែរ"* ។

## តើព្រះអាទិករបានធ្វើកិច្ចការរបស់ទ្រង់យ៉ាងដូចម្តេច?

ព្រះគម្ពីរបានផ្តល់ដល់យើងនូវចម្លើយចំពោះសំនួរ ថាតើព្រះជាម្ចាស់បានបង្កើតចក្រវាលនេះយ៉ាងដូច ម្តេច?

- តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់៖ ទំនុកតម្កើង ៣៣៖៦, យូហាន ១៖១-៤
- បង្កើតចេញពីភាពគ្មានអ្វីសោះ៖ ហេព្រើរ ១១៖៣
- តាមរយៈអំណាចរបស់ព្រះជាម្ចាស់៖ យេរេមា ១០៖១២
- តាមរយៈប្រាជ្ញារបស់ព្រះជាម្ចាស់៖ ទំនុកតម្កើង ១០៤៖២៤, កូលូស ២៖៣
- យោងទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់៖ លោកុប្បត្តិ ១៖២៦, វិវរណៈ ៤៖១១
- តាមរយៈព្រះរាជបុត្រារបស់ព្រះជាម្ចាស់៖ យូហាន ១៖១-៤, យូហាន ១៖១០, កូលូស ១៖១៥-១៧
- យោងទៅតាមចរិតលក្ខណៈរបស់ព្រះយេស៊ូវ៖ ម៉ាថាយ ១១៖២៩, យូហាន ១០៖១១

ចំពោះព្រឹត្តិការណ៍ទាំងនេះបានកើតឡើងក្នុងរយៈពេល៦ថ្ងៃនៃការបង្កើត។ ពួកវាស្ថិតនៅក្រៅដំណើរ ធម្មតានៃច្បាប់ធម្មជាតិ ហើយដូច្នេះគឺយើងអាចយល់បានពេញលេញតាមរយៈសេចក្តីជំនឿ។ តែយ៉ាងណាមិញ ចំពោះច្បាប់ធម្មជាតិដែលបានដឹកនាំកំណត់នៃដំណើរប្រព្រឹត្តិទៅនៃពិភពលោកនេះ ពួកវាមិនមែនជាមូលហេតុដែលបណ្តាលឲ្យកើតមានឡើយ តែវាគ្រាន់តែជាលទ្ធផលនៃការបង្កើត ប៉ុណ្ណោះ។

## ចុះ តើ "ហេតុការណ៍អាក្រក់" កើតឡើងដោយរបៀបណា?

យើងបានដឹងថា ពិភពលោកដែលយើងមើលឃើញបច្ចុប្បន្ននេះគឺមិនមានភាពដូចគ្នាទៅនឹងអ្វីដែល ព្រះជាម្ចាស់បានបង្កើតកាលពីដំបូង រួចទ្រង់មានបន្ទូលម្តងដែលថា "អ្វីៗសុទ្ធតែល្អ" ។ មាន ហេតុការណ៍មួយបានកើតឡើងក្នុងពិភពលោកនេះ ដោយព្រោះតែលទ្ធផលនៃការក្បត់របស់គូរស្វាមី ដំបូងប្រឆាំងជាមួយនឹងអ្នកដែលបានបង្កើតពួកគេមក (លោកុ. ៣)។

## តើមានអ្វីដែលមានប្រទានដល់យើងក្នុងព្រះអម្ចាស់ព្រះយេស៊ូវ

ទ្រង់គឺជាគ្រឹះដែលយើងអាចស្ថាបនាជីវិតរបស់យើង។ ព្រះគ្រីស្ទបានបង្កើតនូវគ្រឹះសម្រាប់អ្វីទាំងអស់ ៖ ការបង្កើតចក្រវាល ព្រះគម្ពីរ សេចក្តីជំនឿ សេចក្តីសង្គ្រោះ សេចក្តីសុខសាន្ត សេចក្តីសង្ឃឹម ជាផ្លូវ ទៅរកព្រះវរបិតា ជាគោលដៅនៃជីវិតរបស់យើង។ ព្រះគ្រីស្ទជាថ្មដាដែលមិនអាចរលំ (១ កូរិនថូស ១០៖៤) ដែលធ្វើឲ្យកិច្ចកល្បរបស់មនុស្សជាតិទាំងអស់នឹងត្រូវបែកបាក់។ ព្រះជាម្ចាស់មានបន្ទូលថា៖ *"អញនឹងបំផ្លាញប្រាជ្ញា របស់ពួកអ្នកប្រាជ្ញ"* (១ កូរិនថូស ១៖១៩)។ វិទ្យាសាស្រ្តខាងគំនិតជាច្រើន ដូចជាការមិនជឿលើព្រះដែលមានទម្រង់ផ្សេងៗពីគ្នា (Atheism) និង ទ្រឹស្តីវិវត្តនិយមនឹងត្រូវខ្ទាត់ ខ្ចាយនៅលើថ្មដានៃព្រះគ្រីស្ទ ។ អ្នកដែលគាំទ្រងចំពោះប្រព័ន្ធគំនិតទាំងអស់នេះនឹងមានថ្ងៃមួយលត់ ជង្គង់ចំពោះព្រះអម្ចាស់ (ភីលីព ២៖១០) ទោះបើជាពេលឥឡូវនេះពួកគេបានបដិសេធចំពោះអ្នកដែល រៀបចំផែនការណ៍ អ្នកដែលបានតាក់តែង អ្នកដែលបានបង្កើត និងជាព្រះសង្គ្រោះក៏ដោយ។

## ហេតុអ្វីបានជាទ្រឹស្តីវិវត្តនិយមមានគ្រោះថ្នាក់ដល់យើង?

ទ្រឹស្តីនេះមិនត្រឹមតែផ្តល់ដល់យើងនូវទស្សនៈយល់ខុសចំពោះពិភពលោកនេះទេ តែវាបានដឹកនាំយើង ទៅរកភាពគ្មានសង្ឃឹម ដូចជាពិពណ៌នាដែលសមហេតុផលរបស់អ្នកនិពន្ធរបស់ជាជាតិអាឡឺម៉ង់ម្នាក់ ឈ្មោះថា ជីន ប៉ូល (Jean Paul) ថា៖ "គឺគ្មានព្រះជាម្ចាស់... សម្លឹងមិនដាក់ភ្នែក, ស្ងៀមស្ងាត់គ្មានអ្វីទាំងអស់! ភាពអស់កល្បដែលត្រជាក់គឺចាំបាច់! ភាពឆ្កួតដោយចៃដន្យ... យើងម្នាក់ៗគឺមានភាព ក្រៀមក្រំក្នុងចក្រវាលដ៏ធំធេងនេះ នេះគឺជាទូដែកនៃសព"។

ទ្រឹស្តីវិវត្តនិយមបានបញ្ជាក់ថា ពិភពលោកយើងនេះអាចពន្យល់បានដោយមិនចាំបាច់មានព្រះអាទិករ។ ជាលទ្ធផលគំនិតនេះ បានទាក់ទាញមនុស្សជាច្រើនឲ្យជឿថាគ្មានព្រះជាម្ចាស់តាំងនៅ (Atheism)។ ហើយដោយយោងទៅតាមអ្វីដែលព្រះយេស៊ូវមានបន្ទូល អ្នកដែលជឿថាគ្មានព្រះជាម្ចាស់តាំងនៅ នឹងធ្លាក់ចូលក្នុងស្ថាននរក៖ *"តែអ្នកណាដែលមិនព្រមជឿ នោះនឹង ត្រូវទោសវិញ"* (ម៉ាកុស ១៦៖១៦)។ មានអ្នកខ្លះបានព្យាយាមដើម្បីពន្យល់ថា ការវិវត្តគឺជាវិធីដែលព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់។ ប៉ុន្តែ ប្រសិនបើព្រះជាម្ចាស់បានបង្កើតការរយៈ ទ្រឹស្តីវិវត្តនិយមនោះ៖

- គ្មានគូរស្វាមីដំបូងឡើយ
- គ្មានអំពើបាប ពីព្រោះថា (ការឈ្លានពានគឺជាគឺជាកងរទេះដែលបានរុញច្រានឲ្យទ្រឹស្តីវិវត្ត និយមឈានទៅមុខ) (Joachim Illies)
- ព្រះជាម្ចាស់នឹងប្រើសេចក្តីស្លាប់ ជាមធ្យោបាយដើម្បីនឹងបង្កើតចក្រវាល
- សេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវ ដែលត្រូវបានហៅថាជា "អ័ដាមចុងក្រោយ" ដែលផ្ទុយពី អ័ដាមដែលពេញដោយបាប (១ កូរិនថូស ១៥៖៤៥) នោះនឹងគ្មានមូលដ្ឋានគ្រឹះនោះឡើយ។

តាមរយៈការពិចារណាទាំងអស់នេះបានបង្ហាញថា "ទ្រឹស្តីវិវត្តនិយម" (Theistic Evolution) នឹងបំផ្លាញនូវមូលដ្ឋានគ្រឹះនៃព្រះបន្ទូលក្នុងព្រះគម្ពីរទាំងស្រុង។ ដោយព្រោះតែមូលហេតុនេះហើយ ដែលទ្រឹស្តីវិវត្តនិយមនេះដែលជាគំនិតខុសនេះគួរតែបដិសេធចោលទាំងស្រុង។

## គំនិតដែលអស្ចារ្យ

យើងបានឃើញថា ព្រះយេស៊ូវជាព្រះអាទិករនៃគ្រប់របស់ទាំងអស់។ ទ្រង់គឺជាព្រះតែមួយដែលបាន គង់នៅអស់កល្បជានិច្ចជាស្តេចនៃអាណាចក្រស្ថានសួគ៌ ។ ទ្រង់បានទទួលអំណាចទាំងអស់ទាំងនៅស្ថានសួគ៌ និងផែនដី (ម៉ាថាយ ២៨៖១៨)។ តើយើងពិតជាអាចយល់ពិតប្រាកដនូវសេចក្តីពិតដ៏អស្ចារ្យ ទាំងនេះបានទេ? មនុស្សម្នាក់ដែលស្ថិតនៅលើឈើឆ្កាងនៃភ្នំកូកូតា និងជាព្រះអាទិករនៃចក្រវាលទាំង មូល និងគ្រប់របស់សព្វសារពើគឺជាមនុស្សតែ១ និងជាមនុស្សដូចគ្នា! នៅក្នុងសេចក្តីស្រលាញ់ដែលមិនអាចគិតស្មានដល់របស់ទ្រង់ ព្រះអម្ចាស់បានប្រទានរូបអង្គទ្រង់ឡើងទៅលើឈើឆ្កាងហើយ មិនរឹងទទឹង ដើម្បីឲ្យទ្វារនៃស្ថានសួគ៌បើកសម្រាប់យើង ។ អស់អ្នកណាដែលបដិសេធចំពោះសេចក្តី នេះនឹងបាត់បង់អ្វីៗទាំងអស់៖ *"នោះធ្វើដូចម្តេចឱ្យយើងរួចបាន បើយើងធ្វេសនឹង សេចក្តីសង្គ្រោះដ៏ធំម្ល៉េះ"* (ហេព្រើរ ២៖៣)។ អស់អ្នកណាដែលទទួលទ្រង់នោះនឹងឈ្នះលើគ្រប់ទាំងអស់៖ *"ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណា ដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ខ្ញុំឱ្យ មកអ្នកនោះមានជីវិត ដ៏នៅអស់កល្បជានិច្ចល ហើយមិន ដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ"*។ ចូរទូលសូមដល់ព្រះយេស៊ូវគ្រីស្ទ ដើម្បីលើកលែងទោសអំពើបាបដល់អ្នក ដើម្បីឲ្យអ្នកអាចឈនៅចំពោះការជំនុំជំម្រះរបស់ព្រះជាម្ចាស់។ ចូរទទួលយកទ្រង់ជាព្រះសង្គ្រោះប្រចាំជីវិតរបស់អ្នក ហើយនឹងដើរតាមសេចក្តីបង្រៀនរបស់ទ្រង់។



លោកបណ្ឌិត (សាស្រ្តាចារ្យ) វែននើរ គីត
នាយកនិងសាស្រ្តាចារ្យនៃ អ្នកពត៌មានវិទ្យាសាស្រ្ត

Original Title: Wer ist der Schöpfer?
Author's home page: www.wernergitt.com

Publisher: Bruderhand Medien
Am Hofe 2; 29342 Wienhausen; Germany
Tel.: +49 (0) 51 49 98 91-0, Fax: -19
E-Mail: info@bruderhand.de | Homepage: bruderhand.de

Nr. 123-63 – Kambodschanisch/Cambodian – 1st edtion 2015



# តើអ្នកណាជាអ្នករចនារបស់ទាំងអស់ក្នុងពិភពលោកនេះ?

## ពិភពលោកដែលយើងមើលឃើញជុំវិញយើង

សូម្បីតែយើងក្រលេកមើលតែមួយភ្លែតទៅលើពិភពនៃជីវិតរស់នៅ បានបង្ហាញយើងនូវភាពធំធេងនៃ គំនិតនៃគោលបំណងដែលខ្ពស់ ជាការរៀបចំដែលពុំគួរឲ្យជឿឡើយ។ សត្វដំរី ទឹកកាមរបស់ត្រីបាឡែន តម្រូវបានបំពាក់ដើម្បីមុជចុះក្នុងជម្រៅ៣០០០ម៉ែត ដោយមិនស្លាប់ ហើយមិនមានបញ្ហាជាមួយនឹងត្រ ចៀករបស់វាឡើយ។ ហើយចាបចិតឈើ បាន យកក្បាលរបស់វាទៅជល់នឹងដើមឈើម្តងហើយម្តង ទៀតដោយគ្មានបញ្ហាបំផ្លាញដល់ខួរក្បាលរបស់វាឡើយ។

ជាទូទៅជីវិតតម្រូវឲ្យមានសរីរាង្គនៃខ្លួនប្រាណ (ដូចជា៖ បេះដូង ថ្លើម ក្រលៀន) ដើម្បីឲ្យមានដំណើរ ការពេញលេញ។ សរីរាង្គទាំងឡាយដែលនៅតែរីកចម្រើន ឬផ្នែកខ្លះដែលបានរីកចម្រើនរួចហើយគឺជា ផ្នែកភាគច្រើនដែលគ្មានប្រយោជន៍ ។ ចំពោះអ្នកគាំទ្រនៃគំនិតរបស់លោកដាវិនភាគច្រើននឹងមានការ ភ្ញាក់ផ្អើល គំនិតនៃការរីកចម្រើននៃសរីរាង្គបានផ្តល់នូវទិសដៅដើម្បីបំពេញគោលដៅអនាគតខ្លះៗ ឬតួនាទីគឺជាការខុសប្លែកទាំងស្រុងចំពោះគំនិតនៃទ្រឹស្តីវិវត្តនិយម។

មានសត្វបក្សីជាច្រើនដែលមានស្វ័យកណធារដែលដឹកនាំពួកគេទៅកាន់គោលដៅរបស់ ពួកគេ ដោយមិនគិតពីអាកាសធាតុ ឬមិនថាជាយប់ឬថ្ងៃនោះឡើយ។ សត្វបក្សីពណ៌មាស (golden plover) បានហើរពី អាឡាស្កាទៅកាន់រដ្ឋហាវ៉ៃនៅរដូវរងារ។ ចំនួន៧០ក្រាមនៃខ្លាញ់តម្រូវសម្រាប ដំណើរ ៤៥០០គីឡូម៉ែត (២៨០០ ម៉ាយ៍) គឺត្រូវបានគណនាយ៉ាងច្បាស់លាស់។



សត្វខ្យងម្យ៉ាង (nautilus) រស់នៅខាងក្រៅនៅចុងសំបកដែលបានបំបែកជា២បន្ទាប់តូចៗ។ បន្ទាប់តូច ៗទាំងនេះបានបំពេញដោយចំនួនជាតិឧស្ម័នផ្សេងៗគ្នា គឺ វាអាស្រ័យថាតើទឹកជម្រៅណាដែលខ្យងគ្រែងមុជចូលទៅក្នុងទឹក ដូច្នេះវាតែងតែធានាថាស្ថិតនៅក្នុងលំនឹងមួយ។ នាវាមុជទឹកសម័យទំនើបរបស់យើងមើលទៅដូចជាឆោតល្ងង់ និងរញេរញៃបើប្រៀបធៀបជាមួយនឹងខ្យង នេះ។ ជាទូទៅសត្វ នេះរស់នៅក្នុងជម្រៅទឹកជ្រៅប្រហែលជា៤០០ម៉ែត ប៉ុន្តែនៅពេលយប់ពួកវាឡើងមកប្រហែលជា ១០០ម៉ែត។

មានអតិសុខុមបាណ្រខ្លះមានភ្ជាប់ជាមួយនឹងសាច់ដុំជំរុញកំលាំងនៃប្រព័ន្ធប្រូតុងដែលអាចធ្វើ ឲ្យពួកវាអាចរំកិលទៅមុខ និងថយក្រោយបាន។ ប្រសិនបើអ្នកជឿ ឬមិនជឿ មានអតិសុខុមប្រាណ មួយដែលមានទំហំត្រឹមតែ ៦លានមីលីម៉ែតគូប ឈ្មោះថា មេរោគអេស្កាវីគី កូលី ដែលមានសាច់ដុំ ជំរុញកំលាំងនៃប្រព័ន្ធប្រូតុងច្រើនជាង៦ ដែលបានភ្ជាប់ជាមួយនឹងកំលាំងដើម្បីបង្កើតជាថាមពល គឺ ដូចជាប្រព័ន្ធរបស់កុំព្យូទ័រដែរ និងរុក្ខជាតិគីមីមួយចំនួនដែលអាចរស់នៅដោយខ្លួនឯងវាបាន។

កោសិការដែលមានជីវិតមួយគឺមានចំនួនច្រើន គឺច្រើនដែលសាំញ៉ាំ និងប៉ិនប្រសព្វជាជាងម៉ាស៊ីនដែល បានបង្កើតដោយមនុស្សទៅទៀត។ នៅក្នុងកោសិការដែលច្រើននោះ គឺមានការរៀបចំតាមលំដាប់នៃ ដំណើរការកម្មវិធីនៃសារធាតុគីមីគឺមានដំណើរការកើតឡើងទាំងអស់ក្នុងពេលជាមួយនឹងគ្មាន ហើយនឹង សម្របសម្រួលរួមគ្នាទៅវិញទៅមក។

រង្វាស់អណ្តូរបស់ឌីអែនអេ (DNA molecules) ដែលមានក្នុងកោសិការដែលរស់មានផ្ទុកនូវព័ត៌មាន នៃកិច្ចការរបស់មនុស្សយ៉ាងច្រើន ។ តើអ្នកដឹងទេថា តើមានចំនួនសៀវភៅក្របស្តើងចំនួន ដែលអាច យកមកផ្ទុកព័ត៌មានដែលមានផ្ទុកក្នុងឌីអែនអេដែលមានទំហំប៉ុនក្បាលម្ជុលមួយ? គឺមានចំនួន ១៥ មីលាន (១៥ million million! )។ ប្រសិនបើអ្នកដាក់សៀវភៅទាំងអស់នេះបន្តុបលើគ្នានៅវានឹងមាន គំនរសៀវភៅ៥០០ដងខ្ពស់ជាងចម្ងាយពីផែនដីទៅព្រះច័ន្ទទៅទៀតគឺមានចំនួនរយៈចម្ងាយសរុបគឺ ១៩២០០០០០០គីឡូម៉ែត (១១៩០០០០០០ម៉ាយ៍)។

នៅក្នុងចក្រវាលរបស់យើងមានផ្កាយប្រមាណ ១០២៥ (= ១ ដែលមានលេខសូន្យចំនួន២៥!)។ សូម្បី តែមនុស្សដែលមានជីវិតរស់នៅយូរជាងគេគឺមិនអាចមានពេលគ្រប់គ្រាន់ដើម្បីនឹងរាប់ចំនួនផ្កាយទាំងអស់នេះដែរ។ ប្រសិនបើយើងបានប្រើប្រាស់កុំព្យូទ័រដែលមានល្បឿនលឿន ដែលអាចមានសមត្ថភាព រាប់បានចំនួន ១០ពាន់លានក្នុងមួយវិនាទី នោះវាត្រូវការចំនួនពេល ៣០លានឆ្នាំដើម្បីរាប់ចំនួនផ្កាយ ទាំងអស់នោះ!

មនុស្សដែលពេញដោយគំនិតដែលបានប្រឈមមុខជាមួយនឹងឧទាហរណ៍ខ្លះៗនេះអាចនឹងមានបំណង ដើម្បីនឹងពិចារណាទៅលើដើមកំណើតនៃគំនិតដែលមានរៀបចំយ៉ាងប៉ិនប្រសព្វទាំងនេះ។ ចំពោះទ្រឹស្តី វិវត្តនិយម ដែលមានមនុស្សជាច្រើនបានទទួលយកនូវទ្រឹស្តីនេះ គឺមិនបានផ្តល់នូវចម្លើយមួយដែល សមហេតុផលនោះឡើយ ពីព្រោះថាទ្រឹស្តីនេះសម្លឹងមើលទៅលើអ្វីៗនៅពេលចុង ក្រោយទាំងអស់ គឺជារូបធាតុ ដែលរួមមានព្រលឹង បញ្ញាចិត្ត និងព័ត៌មានដ៏ច្រើនក្រៃលែងនៅក្នុងកោសិការជាច្រើន។ តាមបែបវិទ្យាសាស្ត្រ យើងបានដឹងថា ព័ត៌មានមិនមែនជារូបធាតុនោះឡើយ ហើយចំពោះច្បាប់ធម្មជាតិទាំងឡាយដែលនិយាយអំពីព័ត៌មានគឺវាតែងតែតម្រូវឲ្យមានប្រភពនៃប្រាជ្ញា (Intelligent Resources) នោះគឺជាអ្នកបង្កើត (ដើមកំណើត) នៃព័ត៌មានទាំងនេះជាមួយនឹងបំណង។ ភាពឆ្លាតវៃ និង ប្រាជ្ញា (Intelligent and wisdom) បានបង្ហាញនូវក្នុងការបង្កើតរបស់ព្រះជាម្ចាស់គឺពិតជាមានភាពអស្ចារ្យមែន ។ ការពិចារណាចំពោះកិច្ចការទាំងនេះបានរុញច្រានយើងដើម្បីធ្វើការសន្និដ្ឋានថា គឺត្រូវតែ មានអ្នកដែលបានបង្កើតគ្រប់របស់ទាំងនេះ អ្នករៀបចំដែលបានទទួលខុសត្រូវចំពោះការរចនានៃ របស់ទាំងអស់។ ប៉ុន្តែ តើជានរណា?

## តើយើងអាចស្វែងរកចម្លើយដែលគួរតែទុកចិត្តបាននៅឯណា?

វិទ្យាសាស្ត្រគឺត្រឹមតែអាចធ្វើការស្រាវជ្រាវនូវការពិតអំពីពេលវេលានិងលំហរ ដែលយើងកំពុងតែរស់ នោះ តាមរយៈការប្រើប្រាស់វិធីផ្សេងៗសម្រាប់វាស់ និងថ្លឹងថ្លែង។ វិទ្យាសាស្ត្រគឺអាចត្រឹមតែពិចារណា អំពី "តើអ្វី?" ប៉ុន្តែមិនអាចដឹងថា "តើមានប្រភពមកពីណា?" អំពីសំនួរនៃការបង្កើតរបស់ព្រះជាម្ចាស់។ ចំពោះចម្លើយនៃសំនួរទី២គឺលើសពីសមត្ថភាពរបស់មនុស្សទាំងអស់ អាចចម្លើយគឺមានតែអ្នកដែល រចនានិងរៀបចំប៉ុណ្ណោះដែលអាចផ្តល់ដល់យើងបាន។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺព្រះគម្ពីរ បាន ផ្តល់ដល់យើងនូវចម្លើយនៅក្នុងខគម្ពីរទី១ថា៖ *"កាលដើមដំបូងឡើយព្រះបានបង្កើត"* ។

ចម្លើយនេះគឺ សមស្របជាមួយនឹងតម្រូវការដែលយើងបានកត់សំគាល់ខាងដើម ដែលរាល់ព័ត៌មានទាំងអស់គឺត្រូវតែ មានប្រភពនៃប្រាជ្ញា (Intelligent Resource)។

## តើអ្នកណាជាអ្នករចនា និងជាអ្នកបង្កើត

ព្រះជាម្ចាស់បានគង់នៅមុនអ្វីៗទាំងអស់ ។ នៅមុនពេលរយៈលំហរ ពេលវេលា និងរូបធាតុទាំងអស់ ទ្រង់គឺសកម្ម។ ប្រសិនបើយើងកំណត់ព្រំដែននូវការពិនិត្យរបស់យើងចំពោះខគម្ពីរខាងលើមួយនេះ យើងអាចមានចំណាប់អារម្មណ៍ថា គឺមានតែព្រះវរបិតាមួយប៉ុណ្ណោះដែលធ្វើក្នុងកិច្ចការនៃការបង្កើត។ តាមរយៈការកំណត់នៃការសម្រេចទ្រង់មិនមែនមានតែមួយអង្គឯងក្នុងការបង្កើតគឺអាចនឹងស្វែងរក ឃើញបន្ថែមទៀតក្នុងបរិបទនៃការបង្កើតរបស់ព្រះជាម្ចាស់៖ *"ចូរយើងបង្កើតមនុស្ស"* (លោកុ. ១៖២៦)។ ព្រះវិញ្ញាណបរិសុទ្ធក៏ជាប់ទាក់ទងជាមួយនឹងការបង្កើតផងដែរ ដូចដែលយើងអាចមើលឃើញនៅក្នុងខទី២នៃការបង្កើត៖ *"...ព្រះវិញ្ញាណនៃព្រះក៏អេរានៅពី លើទឹក"* ។ ព្រះគម្ពីរមិនបានផ្តល់ នូវព័ត៌មានទាំងអស់ក្នុងពេលតែមួយនោះឡើយ តែបទគម្ពីរបានប្រាប់យើងបន្តិចក្នុងពេលមួយ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ចំពោះសំនួរដែលថា "តើជានរណា?" គឺត្រូវបានអធិប្បាយយ៉ាងក្បោះក្បាយ។ ដោយយោងទៅតាមបទគម្ពីរ ១កូរិនថូស ៨៖៦ ព្រះយេស៊ូវគ្រីស្ទគឺទាក់ទងជាមួយនឹងការបង្កើតលោក នេះផងដែរ *"គង់តែខាងយើងមានព្រះតែ ១ ប៉ុណ្ណោះង គឺជាព្រះវរបិតាច ដែលរបស់សព្វសារពើកើត មកពីទ្រង់ ហើយយើងរាល់គ្នាក៏សំរាប់ទ្រង់ ក៏មានព្រះអម្ចាស់តែ១ គឺជាព្រះយេស៊ូវគ្រីស្ទ ដែលរបស់សព្វសារពើកើតមកឈដោយសារទ្រង់ ហើយយើងក៏ដោយសារទ្រង់ដែរ"* ។

ចំពោះពាក្យថា "អេឡូហ៊ីម" (Elohim) ក្នុងបទគម្ពីរ លោកុ.១៖១គឺជាទម្រង់ពហុវចនៈសម្រាប់ អ្នកបង្កើត។ តាមរយៈឧទាហរណ៍នៃការរស់នៅប្រចាំថ្ងៃគឺអាចជួយយើងដើម្បីឲ្យយល់អំពីគំនិត ទាំងឡាយដែលនៅពីក្រោយយោបល់ទាំងនេះ៖ មានគ្រួសារមួយបានជិះឡានទៅសួរសុខទុក្ខមិត្តភ័ក្រ្ត ខ្លះរបស់ពួកគេ។ នៅពេលដែលដល់ពេលវេលាដើម្បីនឹងចាកចេញទៅផ្ទះ ឪពុកបាននិយាយថា៖ "អូខេ! ឥឡូវនេះ ចូរយើងបើកឡានទៅផ្ទះវិញ"។ ទោះបើជាឪពុកបានប្រើទម្រង់ពហុវចនៈ វានៅតែ មានន័យថាគឺមានតែមនុស្សតែម្នាក់ប៉ុណ្ណោះដែលអង្គុយនៅកន្លែងបើកបរ ហើយគាត់ជាអ្នកបើកបរ ។ ចំពោះសមាជិកគ្រួសារដទៃទៀតក៏បានអង្គុយក្នុងឡានដែរ



និងកំពុងតែជិះ ទោះបើមានតែមនុស្សម្នាក់កំពុងតែកាន់ចង្កូត បង្កើនល្បឿន និងជាន់ប្រាំងក៏ដោយ។

នេះគឺជាការបង្ហាញខ្លះៗដែលអាចជួយយើងក្នុងការអំពីរូបភាពនៃព្រះគម្ពីរដែលបានបង្ហាញ ប្រាប់ យើងអំពីព្រះជាម្ចាស់ជាព្រះអាទិករ និងជាអ្នករៀបចំនូវប្រភពនៃអ្វីៗទាំងអស់ដែលយើងឃើញ ក្នុងពិភពលោកនេះ ។ ព្រះជាម្ចាស់បានបង្កើតពិភពលោកនៃជីវសាស្ត្រ តាមរយៈព្រះយេស៊ូវ។ នេះគឺជា ភាពប្រាកដមួយដែលយើងអាចក្នុងបទគម្ពីរ ហេព្រើរ ១៖២ ។ ដំណឹងល្អតាមរយៈសាវ័កយ៉ូហានក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរនៅពេលចាប់ផ្តើម ដែលថាអ្វីៗដែលមានតាំងនៅគឺមានដើមកំណើតរបស់ វាតាមរយៈព្រះយេស៊ូវ។ *"ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វី ណាមួយ កើត មកក្រៅពីទ្រង់ (តាមរយៈព្រះបន្ទូល ដែលជាព្រះយេស៊ូវគ្រីស្ទ)ឡើយ"* (យូហាន ១៖៣)។

## ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអាទិករ

យើងអាចអានបន្ថែមអំពីសកម្មភាពរបស់ព្រះយេស៊ូវនៅក្នុងផ្នែកនៃការបង្កើតរបស់ទ្រង់ដែលស្ថិតនៅ ក្នុងបទគម្ពីរ កូលូស ១៖១៦-១៧ ថា៖ *"ដ្បិតគឺទ្រង់ (ព្រះយេស៊ូវគ្រីស្ទ)ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅ ស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែ កើតមកទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំង អស់ក៏នៅស្ថិតស្ថេរដោយ សារទ្រង់"* ។ នៅក្នុងពិភពលោកដែលអ្នកអាចមើលឃើញនឹងភ្នែកគឺគ្មានអ្វី មួយដែលមិនបានបង្កើតតាមរយៈព្រះយេស៊ូវនោះឡើយ លោកធាតុធំធំមហិមាដោយមានភពរាប់លានគឺវាដូចគ្នាជាមួយនឹងទៅនឹងដំណើរកោសិកាដែលរស់សាំញ៉ាំតូចជាងគេបំផុតដែរ ឬដូចជាទៅនឹង ប្រព័ន្ធចលនារបស់អាតូម។ ព្រះយេស៊ូវមិនត្រឹមតែជាដើមកំណើតនៃលោកធាតុដែលមានទំហំ និងធំ ទាំងអស់នោះឡើយ តែទ្រង់មានអំណាចទៅលើអ្វីៗទាំងអស់។

បន្ថែមលើនេះទៀត ព្រះយេស៊ូវក៏បានបង្កើតពិភពលោកដែលយើងមិនអាចមើលឃើញផងដែរ ទ្រង់ បានបង្កើតនូវចំនួននៃសត្វលោករាប់មិនអស់ និងបង្កនូវចំនួនយ៉ាងច្រើន ដែលព្រះគម្ពីរបានហៅពួកគេ ថាជាពួកទេវតា។ ហើយវាដូចគ្នាទៅនឹងអ្វីៗទាំងអស់នៅក្នុងការបង្កើតរបស់ព្រះជាម្ចាស់គឺ មានភាព ផ្សេងៗពីគ្នា និងមានរចនាសម្ព័ន្ធយ៉ាងខ្ពស់ក្នុងពេលដូចគ្នាដែរ នោះវាក៏មានភាពដូចគ្នាផងដែរជាមួយ អ្វីៗនៅក្នុងលោកីយដែលយើងមើលមិនឃើញ ដូចដែលយើងបានប្រើប្រាស់វាក្យស័ព្ទ បល្ល័ង្ក មេដឹក នាំ និងអំណាច ។

ព្រះយេស៊ូវមិនត្រឹមតែជាព្រះអាទិករប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ជាអ្នកដែលបានគ្រប់គ្រងទៅលើពិភពលោក នេះផងដែរ។ ទ្រង់បានគ្រប់គ្រងអ្វីៗទាំងអស់ជាមួយនឹងគ្នា។ ពិភពលោកនេះមិនបានទុកចោលឲ្យទៅ តាមដំណើរវិវិត្តរបស់វាដោយខ្លួនឯងនោះទេនៅពេលបញ្ចប់នៃការបង្កើតរបស់ទ្រង់ ទ្រង់បានគ្រប់គ្រង និងថែរក្សា តាមរយៈព្រះបន្ទូលដ៏មានអំណាចរបស់ទ្រង់។ ដូច្នេះយើងមិនចាំបាច់មានការបារម្ភចំពោះ ការបំផ្លាញនៃលោកធាតុដែលបណ្តាលមកពីធ្លាក់ចុះនៃអាចម៍ផ្កាយដែលមានទំហំធំ ឬការឡើងនឹងកំដៅ ព្រះអាទិត្យ ឬការធ្លាក់ចុះនៃអាកាសត្រជាក់នោះឡើយ ។ ព្រះយេស៊ូវទ្រង់នឹងគ្រប់គ្រងផែនដីទាំងមូលរហូតដល់ទ្រង់យាងមកវិញ ។

មនុស្សជាតិមិនមែនកើតឡើងតាមរយៈភាពចៃដន្យនៃការលោកធាតុណាមួយ ដូចជាគំនិតរបស់អ្នកឈ្មោះ រង្វាន់ណូបែល លោក ចាក ម៉ូនូប (Jaques Monod) នោះឡើយ។ តែយើងត្រូវបានបង្កើតឡើងដោយ មានគោលបំណង និ